**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.......................................................

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី កិច្ចប្រជុំទ្វេភាគីរវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលថៃ

នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៧ ធនាគារជាតិនៃកម្ពុជាបានរៀបចំកិច្ចប្រជុំទ្វេភាគី រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលថៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា និង ឯកឧត្តម Veerathai Santiprabhob ទេសាភិបាលធនាគារកណ្តាលថៃ ដែលប្រព្រឹត្តទៅនៅខេត្តសៀមរាប។

កិច្ចប្រជុំនេះត្រូវបានប្រារព្ធឡើង ដើម្បីពង្រឹងចំណងសាមគ្គីភាព ភាតរភាព មេត្រីភាព និងកិច្ចសហប្រតិបត្តិការល្អជាប្រពៃណីរវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលថៃ។ គណៈប្រតិភូនៃធនាគារកណ្តាលទាំងពីរ បានពិភាក្សាផ្លាស់ប្តូរយោបល់ពីស្ថានភាពម៉ាក្រូ-សេដ្ឋកិច្ច ការអភិវឌ្ឍ និងបញ្ហាប្រឈមនៅក្នុងវិស័យធនាគារ និងការងារអាទិភាពសំខាន់ៗ ក្នុងការសហការនៅឆ្នាំ២០១៧ និងពេលអនាគត។

ជាលទ្ធផល ធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលថៃ បានប្តេជ្ញាបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការឱ្យកាន់តែរឹងមាំប្រកបដោយចីរភាព សម្រាប់ជាគុណប្រយោជន៍ ដល់ស្ថាប័ននិងប្រទេសទាំងពីរ។ ធនាគារកណ្តាលទាំងពីរបានឯកភាពបន្តផ្លាស់ប្តូរទស្សនកិច្ច ទៅវិញទៅមកដើម្បីផ្លាស់ប្តូរបទពិសោធន៍ល្អៗក្នុងការអភិវឌ្ឍវិស័យធនាគារ។ លើសពីនេះ ធនាគារកណ្តាលថៃក៏បានឯកភាពលើការបន្តរួមចំណែកកសាងធនធានមនុស្ស សម្រាប់ ធនាគារជាតិនៃកម្ពុជា តាមរយៈកម្មវិធីអាហារូបករណ៍ Secondment ចំពោះការត្រួតពិនិត្យ ធនាគារ គោលនយោបាយរូបិយវត្ថុ និងការងារសំខាន់ៗផ្សេងទៀត។

**ទំនាក់ទំនង ៖**
ផ្នែកទំនាក់ទំនង, ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.org.kh